# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍បាត់ដំបង**

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ២២១
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២
<u>សាលដីកា</u>
លេខៈ ៤៣២ (ខ)
ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

# <u>តាងនាមប្រជារាស្ត្រខ្មែរ</u>
# <u>សាលាឧទ្ធរណ៍បាត់ដំបង</u>

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

**ឯកឧត្តម** [redacted] **ប្រធានក្រុមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted] **ព្រះរាជអាជ្ញា**

**ក្រឡាបញ្ជីសវនាការ**

**លោក** [redacted]

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ២២១ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ ដែលមាន៖

១.ជនជាប់ចោទឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសាវជាង ប្រទេសថៃ អាសយដ្ឋានមុនពេលចាប់ខ្លួន [redacted] ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ ឪពុកឈ្មោះ [redacted] (ម) ម្តាយឈ្មោះ [redacted] (ម) ប្រពន្ធឈ្មោះ [redacted] មានកូន ០៥នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុន គ្មាន ។ (ក្នុងឃុំ) (អ្នកប្តឹងឧទ្ធរណ៍)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០០ ព្រ.ទIII "ច"/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ ។

**ជាប់ចោទពីបទ៖** ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.បុគ្គលពាក់ព័ន្ធឈ្មោះ [redacted] មុំ ភេទស្រី កើតថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្នភូមិបន្ទាយ [redacted] ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted] ។ (គេចខ្លួន)

**ជាប់ចោទពីបទ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ដំណើររឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលគោករមៀត បានធ្វើការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនឈ្មោះ [redacted] ឡា ដកហូតបានថ្នាំញៀនម៉ាទឹកកកមួយថង់ទម្ងន់ ៤៦.៣០ ក្រាម និងថ្នាំញៀនគ្រាប់ចំនួនមួយគ្រាប់ ។ ឈ្មោះ [redacted] ឡា បានឆ្លើយសារភាពថាៈ បានទិញថ្នាំញៀនពីឈ្មោះ ធី ឈ្មោះ រី និងឈ្មោះ [redacted] មុំ យកមកប្រើប្រាស់ និងលក់បន្ត ។

**-បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ ០១"ក"/០២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ**

១/-ផ្តន្ទាទោស៖

ក/-ឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសារវជាង ប្រទេសថៃ ។ អាសយដ្ឋានមុនពេលចាប់ខ្លួន [redacted] ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ៥នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុន គ្មាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០០ ព្រ.ទ III "ច" /២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ។

ដាក់ពន្ធនាគារកំណត់រយៈពេល ៥(ប្រាំ)ឆ្នាំ ដោយទោសនេះឱ្យអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ៤(បួន)ឆ្នាំ ទោសនៅសល់ពីនេះឱ្យព្យួរការអនុវត្តធម្មតាតាមមាត្រា ១០៤-១០៩ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល ។

ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ/-ឈ្មោះ [redacted]មុំ ភេទស្រី កើតថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិមាន[redacted] ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted]។ (គេចខ្លួន)

ដាក់ពន្ធនាគារកំណត់រយៈពេល ៤(បួន)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.000.000(បួនលាន)រៀល ។

ពីបទៈជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន ។

២/-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted]មុំ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣/-រឹបអូសៈ ម្សៅក្រាមពណ៌សថ្លាទម្ងន់ ៤៦,៣០ក្រាម (ទម្ងន់ ៤,១៧ក្រាម បានបញ្ជូនទៅធ្វើកោសល្យវិច័យ) មានបរិមាណសុទ្ធ ៣៤,៤៧ ក្រាម និងទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក Vfone ពណ៌ក្រហម ។

*វត្ថុចាប់យកទាំងនេះ ត្រូវបានរក្សាទុកដោយមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ តាមកំណត់ហេតុទទួលវត្ថុតាងលេខ ១១៩ អ.យ.គ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១* ។

៤/-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ឡា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]មុំ ។

ទុកសិទ្ធិប្តឹងទាស់ ឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញៈ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]ឡា ដែលបានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ០១(ក)/០២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ គ្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

-បានឃើញៈ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ។

-បានឃើញៈ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]ឡា (វត្តមាន)

-លោកស្រី [redacted]រដ្ឋា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted]ឡា បានឆ្លើយថា ខ្លួនដឹងពីបទចោទប្រកាន់ហើយ ខ្លួនត្រូវគេចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ខ្លួនមិនសុខចិត្តទេ ព្រោះគ្រឿងញៀនមិនមែនជារបស់ខ្លួន ។

ខ្លួនយកខោអាវទៅបោកអ៊ុតមែន ប៉ុន្តែខោអាវនោះមិនមែនជារបស់ខ្លួនទេ ។ ប៉ូលីសឆែកឆេរខ្លួនបានថ្នាំញៀនមួយគ្រាប់ ដែលខ្លួនទិញពីឈ្មោះ [redacted] មុំ ។ ឈ្មោះ [redacted] មុំ នោះ ខ្លួនអត់ដឹងទៅណាទេ ។ ខោអាវដែលខ្លួនយកទៅបោកអ៊ុត គិតជាគីឡូ ហើយខ្លួនយកទៅបោកពេលព្រឹក ។ ខ្លួនសំណូមពរ ឱ្យតុលាការមេត្តាដោះលែងខ្លួនផង ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា តំណាងមហាអយ្យការនៅរក្សាបទចោទប្រកាន់លើជនជាប់ចោទដដែល និងជូនក្រុមប្រឹក្សាជំនុំជម្រះ ពិចារណា និងសម្រេចទៅតាមនីតិវិធីច្បាប់ ។

-លោកស្រី [redacted] រដ្ឋា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា យោងតាមឯកសារនៅក្នុងសំណុំរឿង កូនក្តីខ្លួនបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ គឺកូនក្តីខ្លួនមានភាពភ័យខ្លាចចេះតែឆ្លើយទៅ ។ ហើយកូនក្តីខ្លួនទទួលស្គាល់គ្រឿងញៀនតែពីរគ្រាប់ទេ ។ រឿងនេះនៅមានវិមតិសង្ស័យនៅឡើយ ។ កូនក្តីខ្លួនមានកូននៅក្នុងបន្ទុក ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចបដិសេធសាលក្រមរបស់សាលាដំបូងខេត្តបន្ទាយមានជ័យចោលជាអសារបង់ និងសម្រេចជាថ្មី ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង</u>

## <u>យល់ឃើញថា</u>

១.ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ឡា ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៨២ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.តាមអង្គហេតុនៃការចោទប្រកាន់បានបញ្ជាក់ថា កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០និង០០នាទី ឈ្មោះ [redacted] ហួរ ហៅ ញ៉ាញ់ ដែលជាអ្នករកស៊ីបោកអ៊ុតខោអាវ បានជិះម៉ូតូទៅយកខោអាវមកបោកអ៊ុតដូចសព្វដង ហើយបានទៅយកខោអាវពីផ្ទះថៃម្នាក់នៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដោយម្ចាស់ខោអាវបានប្រមូលខោអាវដាក់ក្នុងថង់ខ្មៅ ប្រគល់មកឱ្យឈ្មោះ [redacted] ហួរ ហើយឈ្មោះ [redacted] ហួរ បានយកខោអាវនោះមកបោកអ៊ុតនៅផ្ទះរបស់ខ្លួន ។ នៅពេលដែលឈ្មោះ [redacted] ហួរ បានដាក់ខោអាវចូលក្នុងម៉ាស៊ីន បោកបានពាក់កណ្តាលក៏ប្រទះឃើញថង់ពណ៌ខ្មៅមួយនៅក្នុងថង់ខោអាវនោះ ហើយក៏បានយកថង់ពណ៌ខ្មៅនោះមកស្រាយមើល ឃើញមានម្សៅ

ពណ៌សច្រកថង់មួយដុំ និងកូនថង់តូចៗជាច្រើន ហើយដោយមានការសង្ស័យថា ជាគ្រឿងញៀនឈ្មោះ [redacted] ហួរ ក៏បានរាយការណ៍ដល់សមត្ថកិច្ចរហូតដល់មានការចាប់ឃាត់ខ្លួនឈ្មោះ [redacted]ឡា តែម្តង ។

៣.ជនជាប់ចោទឈ្មោះ [redacted]ឡា បានឆ្លើយចំពោះមុខអយ្យការ ចៅក្រមស៊ើបសួរ និងពេលសវនាការនៅសាលាដំបូងខេត្តបន្ទាយមានជ័យ ក៏ដូចជាពេលសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបងដែរ ថា ខ្លួនមិនបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនដូចការចោទប្រកាន់ឡើយ ហើយគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាននេះ ពុំមែនជារបស់ខ្លួនទេ ។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ម៉ោងប្រហែលជាង ១០ ទៅ ១១ថ្ងៃត្រង់ ខ្លួនកំពុងតែបោសផ្ទះ ស្រាប់តែសមត្ថកិច្ចចូលទៅឃាត់រូបខ្លួន ហើយបញ្ជូនខ្លួនមកប៉ុស្តិ៍ភ្លាមដោយមិនបានឆែកឆេរផ្ទះ និងខ្លួនប្រាណខ្លួនទេ ។ ពេលមកដល់ប៉ុស្តិ៍គេសួរចម្លើយ ហើយបញ្ជូនខ្លួនមកស្រុកថ្មពួក ទើបបង្ហាញគ្រឿងញៀនថា ជារបស់ខ្លួន ដែលដកពីខោអាវដែលខ្លួនដាក់ឱ្យគេបោក ។ ខ្លួនសូមបដិសេធថា គ្រឿងញៀនមិនមែនជារបស់ខ្លួនទេ ។

៤.តាមចម្លើយបំភ្លឺរបស់ឈ្មោះ [redacted] ហួរ ហៅ ញ៉ាញ់ ដែលជាអ្នកយកខោអាវមកបោកអ៊ុត និងឃើញគ្រឿងញៀន និងជាអ្នកបានរាយការណ៍ជូនសមត្ថកិច្ចបានបញ្ជាក់ថា ៖នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០ និង០០នាទី ខ្លួនបានជិះម៉ូតូដើរយកខោអាវមកបោកអ៊ុតដូចសព្វដងនៅតាមភូមិ ខ្លួនបានទៅយកខោអាវនៅផ្ទះថៃម្នាក់ នៅភូមិវល្លិ៍ប្រេង(ក្រចកអណ្តើក) ពុំស្គាល់ឈ្មោះ ដឹងត្រឹមថា គាត់ជាកូនប្រសាររបស់ថៃវ៉ាត់ម្ចាស់លានដំឡូងភូមិវល្លិ៍ប្រេង ហើយថៃម្ចាស់ខោអាវគាត់បានប្រមូលខោអាវដាក់ចូលក្នុងថង់ខ្មៅធំមួយលើកមកឱ្យខ្លួន ខ្លួនក៏បានដឹងខោអាវនោះមកផ្ទះ ហើយមិនបានដើរយកខោអាវកន្លែងផ្សេងទៀតទេ ខ្លួនក៏រៀបចំរើខោអាវនោះចេញពីថង់ខ្មៅធំនោះ ដើម្បីដាក់ចូលម៉ាស៊ីនបោក ខ្លួនបានយកខោអាវដាក់ចូលម៉ាស៊ីនអស់ប្រហែលពាក់កណ្តាល ហើយខ្លួនបម្រុងលើកយកខោអាវដែលនៅសល់ក្នុងថង់ស្រាប់តែឃើញមានថង់ដៃពណ៌ខ្មៅមួយនៅក្រោមខោអាវក្នុងថង់ខ្មៅធំដាក់ខោអាវនោះ ខ្លួនចង់ដឹងថង់នោះមានអ្វី ក៏យកដាក់លើពាងស្រាយមើល ក៏ឃើញមានម្សៅពណ៌សច្រកថង់មួយដុំ និងមានថង់ពណ៌សតូចៗជាច្រើន ឃើញដូចនោះខ្លួនមានការសង្ស័យថា ជាគ្រឿងញៀនក៏មករាយការណ៍ជូនសមត្ថកិច្ចឱ្យទៅមើល ពេលសមត្ថកិច្ចទៅដល់គាត់ក៏បានពិនិត្យម្សៅសក្នុងថង់នោះ ពួកគាត់ក៏យកមកប៉ុស្តិ៍ និងបានហៅខ្លួនមកសាកសួររឿងហេតុ ។ អង្គុយបានមួយសន្ទុះប្រពន្ធខ្លួនបានតេតាមទូរស័ព្ទមកសួរនាំខ្លួនថា មានថៃម្ចាស់ខោអាវថង់ខ្មៅនោះ មកសួរថា មានឃើញកញ្ចប់ឥវ៉ាន់ក្នុងថង់ខោអាវឬអត់ ។ ខ្លួនក៏បាននិយាយប្រាប់ប្រពន្ធខ្លួនថា មិនឃើញទេ ហើយខ្លួនក៏បានបិទទូរស័ព្ទទៅ ព្រោះខ្លួនកំពុងរាយការណ៍ជូនសមត្ថកិច្ចខ្លាចបែកការណ៍ ។

៥.តាមចម្លើយបំភ្លឺរបស់ឈ្មោះ [redacted] ហួរ ហៅ ញ៉ាញ់ ខាងលើនេះ បានបញ្ជាក់ឱ្យឃើញថា អ្នកដែលយកខោអាវឱ្យឈ្មោះ [redacted]ហួរ បោកអ៊ុត និងអ្នកដែលបានមកសួររកកញ្ចប់គ្រឿងញៀនក្នុងថង់ខ្មៅធំដាក់ខោអាវ គឺជាមនុស្សស្រី ដែលផ្ទុយពីជនជាប់ចោទឈ្មោះ [redacted] ឡា ដែលជាមនុស្សប្រុស ។

៦.តាមចម្លើយរបស់ជនជាប់ចោទ តាមការបំភ្លឺរបស់សាក្សី និងតាមឯកសារភស្តុតាងនៅក្នុងសំណុំរឿងឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដែលលើសពីវិមតិសង្ស័យ ដែលអាចបញ្ជាក់បានថា ឈ្មោះ [redacted] ឡា បានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ឡើយ ។

៧.អង្គហេតុដែលសាលាដំបូងខេត្តបន្ទាយមានជ័យ លើកយកមកធ្វើការចោទប្រកាន់លើជនជាប់ចោទ បញ្ជាក់ថា កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលគោករមៀត បានធ្វើការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនឈ្មោះ [redacted] ឡា ដកហូតបានម៉ាទឹកកកមួយថង់ទម្ងន់ ៤៦,៣០(សែសិបប្រាំមួយកណ្តាក់សញ្ញាសាមសិប)ក្រាម និងថ្នាំញៀនគ្រាប់ចំនួន ០១គ្រាប់ ដែលអង្គហេតុនេះ ខុសពីអង្គហេតុដែលបានលើកឡើងដោយឈ្មោះ [redacted]ហួរ និង មន្ត្រីនគរបាលយុត្តិធម៌ ។

៨.ការសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] ឡា របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានផ្អែកតែលើចម្លើយរបស់ឈ្មោះ [redacted] ឡា នៅមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែចម្លើយនេះត្រូវបានជនជាប់ចោទបដិសេធតាំងពីដំណាក់កាលអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យមក ហើយតាមការបំភ្លឺរបស់សាក្សីបានបញ្ជាក់ថា អ្នកយកខោអាវមកបោកអ៊ុត និងសួររកកញ្ចប់គ្រឿងញៀនជាមនុស្សភេទស្រី ដែលអាចបញ្ជាក់ថា ចម្លើយរបស់ជនជាប់ចោទនៅមន្ត្រីនគរបាលយុត្តិធម៌ពុំអាចឱ្យជឿបានឡើយ ។

៩.គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើឈ្មោះ [redacted]ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសាវដាង ប្រទេសថៃ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted]ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted]មានកូន ០៥នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុន "គ្មាន" ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ឡើយ ដែលគប្បីឱ្យឈ្មោះនេះរួចផុតពីបទចោទប្រកាន់នេះ ។

១០.ការដែលសាលាដំបូងសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]ឡា ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នេះ ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍បាត់ដំបង យល់ឃើញថា ពុំមានលក្ខណៈគ្រប់គ្រាន់ទេ ព្រោះតាម



Scanned with CamScanner

បញ្ញត្តិនៃមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា "ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦(ប្រាំមួយ)ខែ និងអាចត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀល ទៅ ១.០០០.០០០(មួយលាន)រៀល" ហើយតាមការពិនិត្យឯកសារដែលមានក្នុងសំណុំរឿង ពុំឃើញមានភស្តុតាងជាឯកសារណាមួយដែលបញ្ជាក់ថា ជនជាប់ជាប់ចោទឈ្មោះ [redacted] ឡា ធ្លាប់ត្រូវទទួលរងនូវវិធានការព្យាបាលដោយបង្ខំនោះទេ ។ ដូច្នេះ ពុំមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើជនជាប់ចោទឈ្មោះឈ្មោះ [redacted] ឡា ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ឡើយ ។

១១.គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសាវដាង ប្រទេសថៃ អាសយដ្ឋានមុនពេលចាប់ខ្លួន [redacted] ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០៥នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុន "គ្មាន" ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ឡើយ ដែលគប្បីឱ្យឈ្មោះនេះ រួចផុតពីបទចោទប្រកាន់នេះ ។

១០.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានធ្វើសេចក្ដីសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ឡា ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ដែលសាលាឧទ្ធរណ៍បាត់ដំបងទទួលជំនុំជម្រះបាន ។ តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង សន្និដ្ឋានប្ដឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍បាត់ដំបង សម្រេចតាមនីតិវិធីច្បាប់ ។

១១.សាលក្រមព្រហ្មទណ្ឌលេខ ០១ "ក"/០២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលសម្រេចសេចក្ដីមកនេះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដែលគប្បីបដិសេធចោលជាអសារបង់ ។

## ហេតុដូច្នេះទិនិច្ឆ័យសេចក្ដី

១. ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ឡា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. បដិសេធ សាលក្រមព្រហ្មទណ្ឌលេខ ០១ "ក"/០២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣. ឱ្យឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសាវជាង ប្រទេសថៃ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted]ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ[redacted]) ប្រពន្ធឈ្មោះ[redacted]ានកូន ០៥នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុន គ្មាន រួចផុតពីបទចោទប្រកាន់ ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ។

៤.បង្គាប់ឱ្យដោះលែងឈ្មោះ[redacted] ឡានេះចេញពីមន្ទីរឃុំឃាំងជាបន្ទាប់ ប្រសិនបើឈ្មោះនេះ មិនត្រូវបាន ឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ ។

-សាលដីកានេះប្រកាសជាសាធារណៈ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា[redacted] | ហត្ថលេខា[redacted] , [redacted] | ហត្ថលេខា[redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

បាត់ដំបង ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner